# លក្ខខន្តិកៈ

## ការធានារ៉ាប់រង អាយុជីវិតប៊ីម៉ា

**<u>នរណានឹងទទួលបានការធានា?</u>**

ការធានារ៉ាប់រង អាយុជីវិតប៊ីម៉ា-ម្ចាស់ប័ណ្ណសន្យារ៉ាប់រង នឹងសាច់ញាតិដែលជាអ្នកទទួលផលសំណងធានារ៉ាប់រងជីវិតទាំងអស់ត្រូវតែមានឈ្មោះនៅក្នុងគោលការណ៍ដើម្បីទទួលការធានារ៉ាប់រងនេះ ។

**<u>អាយុ:</u>**

អាយុដែលអាចធ្វើការចុះឈ្មោះសេវាកម្មបានពីអប្បបរមាគឺ 18 រហូតដល់អាយុអតិបរមា 59 ឆ្នាំ, ឧទាហរណ៍៖ អតិថិជនដែលមានអាយុ 59ឆ្នាំ មិនអាចធ្វើការចុះឈ្មោះបានទេ ។ ការធានានឹងបញ្ឈប់ការផ្តល់ជូននៅអាយុ 60ឆ្នាំ ។

**<u>ការកាត់ទឹកប្រាក់ និង ការធានា:</u>**

- លក្ខខណ្ឌនៃការប្រើប្រាស់ ដើម្បីទទួលបានការធានាត្រូវបង់បុព្វលាភជាសាច់ប្រាក់នៅពេលចុះឈ្មោះជាមួយមន្ត្រីផ្នែកលក់របស់យើង។
- ដើម្បីត្រូវទទួលបានការធានា, សំរាប់អត្ថប្រយោជន៍ដែលត្រូវបានផ្តល់ជូនគឺករណីមរណៈភាព
- កញ្ចប់នៃការធានារួមមាន 3, 6, រឺ 12ខែ និង អាចបន្តប្រើប្រាស់ជាថ្មីនៅខែចុងក្រោយនៃការធានាដែលបានទិញនីមួយៗ
- អតិបរមានៃកញ្ចប់សេវាកម្មគឺមានត្រឹមតែ12ខែ, ប៉ុន្តែការធានាលើសពី12ខែត្រូវបានផ្តល់ជូន (ជាមួយនឹងការផ្តល់ជូនបន្ថែមឥតគិតថ្លៃ), គោលការណ៍ធានាត្រូវបានចែកចេញជាពីរសំរាប់ម្ចាស់សន្យារ៉ាប់រង
- ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញ គឺត្រូវរង់ចាំរយៈពេល 30ថ្ងៃបន្ទាប់ពីការចុះឈ្មោះ ។ ឧទាហរណ៍: អតិថិជនចុះឈ្មោះនៅថ្ងៃទី 02 ខែតុលា ហើយគាត់នឹងទទួលបានការធានាពេញលេញនៅថ្ងៃទី 02 ខែវិច្ឆិកា ។ ករណីធ្វើការចុះឈ្មោះរួច អតិថិជនត្រូវរង់ចាំ 30ថ្ងៃ តែក្នុងរយៈពេលរង់ចាំនោះ មីលវីក(Milvik) នឹងផ្តល់ជូននូវការធានាលើអាយុជីវិត100% សំរាប់ម្ចាស់បណ្ណ័ផ្ទាល់ក្នុងករណីគ្រោះថ្នាក់ចៃដន្យ, លើកលែងករណីគ្រោះធម្មជាតិ និងជំងឺមិនត្រូវបានផ្តល់ជូនក្នុងរយៈពេលនេះទេ។ ករណីគ្រោះថ្នាក់ចៃដន្យមានន័យថា អ្វីដែលកើតឡើងដោយមើលមិនឃើញ ភ្លាមៗ មិនបានត្រៀមជាមុន និង ឧប្បត្តិហេតុផ្សេងៗ ។

**<u>ការទាមទារសំណង:</u>**

- ដំណើរការនៃការផ្តល់សំណង និងផ្តល់ជូនបន្ទាប់ពីឯកសារត្រូវបានដាក់ជូនដូចខាងក្រោម៖
    - ភស្តុតាងនៃការចុះឈ្មោះធានារ៉ាប់រង
    - ភស្តុតាងបញ្ជាក់អត្តសញ្ញាណ(អាយុ)
    - ឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកទទួលផលសំណង
        - ឯកសារបញ្ជាក់អត្តសញ្ញាណដូចជា: អត្តសញ្ញាណបណ្ណ រឺ សៀវភៅគ្រួសារ បណ្ណំបើកបរ រឺ លិខិតឆ្លងដែន ។
    - ភស្តុតាងបញ្ជាក់ការទទួលមរណៈភាព
        - ភស្តុតាងបញ្ជាក់ពីមរណៈភាពរួមមាន: លិខិតមរណៈភាព លិខិតបញ្ជាក់ពីគ្រូពេទ្យអំពីមូលហេតុនៃការស្លាប់ រឺ លិខិតផ្លូវការពីមេភូម រឺ ចៅសង្កាត់ដែលមានសិទ្ធ
    - អតិថិជនអាចទំនាក់ទំនងមកក្រុមហ៊ុនប៊ីម៉ា តាមរយៈលេខទូរសព្ទ័ រឺក៏អាចមកក្រុមហ៊ុនផ្ទាល់

## ករណីមិនធានា:

- ប៊ីម៉ានឹងមិនធ្វើការផ្តល់សំណងជូន ប្រសិនបើករណីមរណៈភាពបានកើតឡើងដោយផ្ទាល់ រឺ ប្រយោលបណ្តាលមកពី៖
- ការធ្វើអត្តឃាតខ្លួនឯង
- សង្គ្រាម ការបះបោរ កុប្បកម្ម រឺ ការចលាចលក្នុងសង្គមស៊ីវិល
- ការប្រព្រឹត រឺ បង្កឱ្យមានបទឧក្រិដ្ឋ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ជាតិអាកុល រឺជាតិញៀនផ្សេងៗក្រៅពីវេជ្ជបញ្ជារបស់គ្រូពេទ្យ
- មិនបានបង្ហាញ រឺ លាក់បាំងពីស្ថានភាពជំងឺដែលមានស្រាប់នៅពេលចុះឈ្មោះ រឺជាប្រភេទជំងឺរ៉ាំរ៉ៃ ។ អ្នកដែលត្រូវទទួលបានការធានា ត្រូវមានសុខភាពល្អនៅពេលចុះឈ្មោះ ។

## ការលុបចោលការធានា:

ម្ចាស់បណ្ណ័សន្យារ៉ាប់រង អាចធ្វើការលុបចោលនៅគោលការណ៍ធានារ៉ាប់រងបានដោយធ្វើការទាក់ទងទៅកាន់ផ្នែកបម្រើសេវាអតិថិជនរបស់ប៊ីម៉ា ។ ម្ចាស់បណ្ណ័សន្យារ៉ាប់រង អាចធ្វើការជ្រើសរើសការធានាដែលមិនមានកាលកំណត់ រឺជ្រើសរើសការបង្វិលប្រាក់បុព្វលាភជូនវិញនៅពេលលុបចោល ។ ប្រសិនបើម្ចាស់ប័ណ្ណសន្យាធានារ៉ាប់រង ជ្រើសយកការបង្វិលថ្លៃប្រាក់បុព្វលាភជូនវិញ ប៊ីម៉ា ត្រូវបង្វិលប្រាក់បុព្វលាភជូនវិញចំនួន៩០% នៃប្រាក់បុព្វលាភក្នុងរយៈពេលដែលបានបង់រួច ដោយការធានាមិនទាន់ត្រូវបានផ្តល់ជូននៅឡើយ បើមិនទាន់បានរៀបចំឯកសារទាមទារសំណងទេនោះ។ ប្រសិនបើវាត្រូវបានរៀបចំឯកសារទាមទារសំណងរួចហើយ នោះមិនមានការបង្វិលប្រាក់សងត្រឡប់វិញទេ នៅពេលមានការលុបប័ណ្ណសន្យាធានារ៉ាប់រងចោល។